# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

**លេខ ២៦៧ ប្រ.ក**

## ប្រកាស

### ស្តីពី

ការបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌នៃព្រះរាជាណាចក្រកម្ពុជា

“ រមណីយដ្ឋានបុរាណវិទ្យាភ្នំចាស់ ”

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភូមិបាល។
- បានឃើញអនុក្រឹត្យលេខ៩៨អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការអនុវត្តកិច្ចការពារបេតិភណ្ឌវប្បធម៌។
- បានឃើញអនុក្រឹត្យលេខ២៤អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

- បានឃើញសារាចរណែនាំលេខ០៥ស.រ.ណ.ស ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីបំរាមធ្វើអាជីវកម្មរុករក និងបំផ្លាញវត្ថុបុរាណ ។
- យោងតាមការចាំបាច់របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

**សម្រេច**

**ប្រការ ១ :**

ត្រូវបានចុះក្នុងបញ្ជីសារពើភណ្ឌបេតិភណ្ឌវប្បធម៌ជាតិនូវទីតាំង"**ភ្នំចាស់**"ជារមណីយដ្ឋានបុរាណវិទ្យា ដែលមានទីតាំង ស្ថិតក្នុងភូមិសាស្ត្រឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

**ប្រការ ២ :**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គឺជានីតិបុគ្គលសាធារណៈ ដែលមានសមត្ថកិច្ចធ្វើសំណើសុំវិញ្ញាបនបត្រ សំគាល់ម្ចាស់អចលនវត្ថុ និងប័ណ្ណសំគាល់សិទ្ធិកានកាប់អចលនវត្ថុពីរដ្ឋបាលសុរិយោដីនូវទីតាំងរមណីយដ្ឋាន បុរាណវិទ្យា "**ភ្នំចាស់**" ជាទ្រព្យសម្បត្តិសាធារណៈ ។

**ប្រការ ៣ :**

ដែនការពាររមណីយដ្ឋានបុរាណវិទ្យា "**ភ្នំចាស់**" ត្រូវកំណត់ក្នុងប្រកាសមួយដោយឡែក បន្ទាប់ពីសម្រប សម្រួលជាមួយនឹងរដ្ឋបាលខេត្តកំពង់ស្ពឺ ។

**ប្រការ ៤ :**

នាយកខុទ្ទកាល័យ អធិការ សវនករផ្ទៃក្នុង អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបេតិភណ្ឌ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ សាកលវិទ្យាធិការនៃសាកលវិទ្យា ល័យភូមិន្ទវិចិត្រសិល្បៈ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺមានភារកិច្ច អនុវត្តតាមប្រកាសនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រាជធានីភ្នំពេញ ;ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩**

**<u>ចម្លងជូន</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទការិយាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទការិយាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ
"ដើម្បីជូនជ្រាបដ៏ខ្ពង់ខ្ពស់"
-គ្រប់ក្រសួងស្ថាប័ន
"ដើម្បីជូនជ្រាប"
-សាលរាជធានី និងគ្រប់សាលាខេត្ត
-ដូចប្រកាត៤
"ដើម្បីមុខការ"
-មន្ទីរប្បធម៌ និងវិចិត្រសិល្បៈរាជធានី និង គ្រប់ខេត្ត
"ដើម្បីជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**